ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
****
សំណុំរឿងព្រហ្មទណ្ឌលេខ: ១១០៧
ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០២១
សំណុំរឿងស៊ើបសួរលេខ: ៧៨៤
ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០២១
សំណុំរឿងជំនុំជម្រះលេខ: ៣៤១
ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០២២
សាលក្រមព្រហ្មទណ្ឌលេខ: ៥៥៣ "ឧ"
ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២២

តារាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ស្ពឺ។
-កាលបរិច្ឆេទបើកសវនាការ: ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០២២ វេលាព្រឹក។
-កាលបរិច្ឆេទប្រកាសសាលក្រម: ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២២ វេលាព្រឹក។

ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូង

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះលើជនជាប់ចោទ:

១.ឈ្មោះ [redacted] សាវុធ ភេទប្រុស អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ សាសនាព្រះពុទ្ធ។ ទីកន្លែងកំណើតភូ[redacted]ខេត្តកំពត។ ទីលំនៅបច្ចុប្បន្នមុនចាប់ខ្លួននៅភូមិវាលធំ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ឪពុកឈ្មោះ [redacted] សាម៉ែត (ស) ម្តាយឈ្មោះ [redacted]ណាវី (ស) ប្រពន្ធឈ្មោះ [redacted] វណ្ណា (រ) មានកូន ០៤នាក់ ទោសពីមុន គ្មាន។ (ឃុំខ្លួន)

ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តកំពង់ស្ពឺ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៧៨១ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

២.ឈ្មោះ [redacted] ចាន់ដេត ភេទប្រុស ឆ្នាំកំណើត១៩៨៩ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ១០០៧១៧៨៤៩។ ទីកន្លែងកំណើត[redacted]ខេត្តកំពង់ស្ពឺ។ ទីលំនៅបច្ចុប្បន្ននៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ។ (គេចខ្លួន)

ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ ចេញ ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ: ១៣៣ ដបច ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២។

ជាប់ចោទពីបទ: រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលធំ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ និងទោសដែលមានចែងក្នុងមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការគ្រួតពិនិត្យគ្រឿងញៀន។

-តាមដីកាដំណោះស្រាយលេខ: ២៩៩ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ឈ្មោះ [redacted] សាវុធ។

ឯអង្គហេតុកើតមានឡើងដូចតទៅ: កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៧ និង ៣០នាទីរសៀល នៅចំណុចភូមិវាលធំ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កម្លាំងនគរបាលមន្ទីរ

ប្រឆាំងបទល្មើសគ្រឿងញៀន បានធ្វើបង្ក្រាបករណី រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ឃាត់ខ្លួនជនសង្ស័យបានចំនួន ០១នាក់ ឈ្មោះ [redacted] សាវុធ បានធ្វើសកម្មភាពទិញគ្រឿងញៀនពីឈ្មោះ ឈិត ចាន់ដេត តម្លៃ ៣០០.០០០(សាមសិបម៉ឺន)រៀល ដើម្បីយកទៅប្រើប្រាស់ និងលក់បន្ត ទើបត្រូវបានសមត្ថកិច្ចធ្វើការឆែកឆេរ ដោយដកហូតគ្រឿងញៀនបានចំនួន ០២កញ្ចប់ និងទូរស័ព្ទ ០១គ្រឿង។ តាមចម្លើយសារភាពរបស់ជនសង្ស័យឈ្មោះ [redacted] សាវុធ បានឆ្លើយថា ខ្លួនធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ [redacted] ពីមុនមក លុះសមត្ថកិច្ចចាប់ឈ្មោះ [redacted] បាន ទើបប្តូរមកទិញគ្រឿងញៀនពីឈ្មោះ [redacted] ចាន់ដេតវិញ។

នាពេលសវនាការ

ក្រោយពីបាន:

-ស្តាប់ និងសួរចម្លើយជនជាប់ចោទឈ្មោះ [redacted] សាវុធ

-ស្តាប់ក្រឡាបញ្ជីអានរបាយការណ៍ និងកំណត់ហេតុផ្សេងៗទៀត

-ស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ស្តាប់ជនជាប់ចោទសំណូមពរផ្សេងៗ

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១.តាមរបាយការណ៍ស៊ើបអង្កេតរបស់សមត្ថកិច្ចនគរបាលយុត្តិធម៌ និងចម្លើយសារភាពរបស់ជនជាប់ចោទ រួមទាំងភស្តុតាងមួយចំនួនបានបង្ហាញឲ្យឃើញថា: កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៧ និង៣០នាទីរសៀល កម្លាំងនគរបាលមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានធ្វើការបង្ក្រាបករណី រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ឃាត់ខ្លួនឈ្មោះ [redacted] សាវុធ ភេទប្រុស អាយុ ៤៥ឆ្នាំ ធ្វើការដកហូតក្រាមសថ្លា(មេតំហ្វេតាមីន)ទម្ងន់ ៣.៥៨ក្រាម និងក្រាមសថ្លា(មិនច្បាស់)ទម្ងន់ ៨.៤៤ ច្បាស់)ទម្ងន់ ៨.៤៤ក្រាម និងទូរស័ព្ទដៃ ០១គ្រឿង។

២.តាមកំណត់ហេតុ បើក រាប់ ថ្លឹង ដក និងបិទកញ្ចប់គ្រឿងញៀន ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ នៅសាលាដំបូងខេត្តកំពង់ស្ពឺ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សាវុធ ដែលមានគ្រឿងញៀន ០២ប្រភេទកញ្ចប់ទី១ ក្រាមសថ្លា(មេតំហ្វេតាមីន)ទម្ងន់ ៣.៥៨ក្រាម និងក្រាមសថ្លា(មិនច្បាស់)ទម្ងន់ ៨.៤៤ ក្រាម។

តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ: ៣៤៣១៦/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជារបស់ជនជាប់ចោទឈ្មោះ [redacted] សាវុធ លទ្ធផល វិជ្ជមាន វត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន(Metamfetamine) បរិមាណសារធាតុគិតជាភាគរយនៃទម្ងន់ ៧៤.៥៩%(ចិតសិបបួន កណ្តាក់សញ្ញា ហាសិបប្រាំបួនភាគរយ)។

៣.ជនជាប់ចោទឈ្មោះ [redacted] សាវុធ បានឆ្លើយសារភាពថាពិតជាបានរកស៊ីទិញ លក់ថ្នាំញៀនតាំងពីដើមឆ្នាំ២០២១ ថ្នាំញៀនទិញពីឈ្មោះ អូន និងឈ្មោះ [redacted] ចាន់ដេត។ ជនជាប់ចោទបានទិញថ្នាំញៀន ដើម្បីយកមកលក់បន្ត និងជក់ខ្លួនឯងផង។ អ្នកដែលទិញថ្នាំញៀនពីជនជាប់ចោទជាតែកុងរថយន្តកុងទីន័រ។ នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ បានជិះម៉ូតូឌុបទៅទិញគ្រឿងញៀនពីឈ្មោះ [redacted] ចាន់ដេត ០២កញ្ចប់តម្លៃ ៣០០.០០០(សាមសិបម៉ឺន)រៀល យកមកលក់ និងជក់ដូចមុន ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន។

៤.មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សាវុធ និងឈ្មោះ [redacted] ចាន់ដេត តាមទម្រង់ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលធំ ឃុំត្រែងត្រយឹង ស្រុក

Scanned with CamScanner

ភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ និងទោសដែលមានចែងក្នុងមាត្រា ៤០ និងមាត្រា ៥៥ នៃច្បាប់ស្តីពីការគ្រួតពិនិត្យគ្រឿងញៀន។

៥.ជនជាប់ចោទឈ្មោះ [redacted] ចាន់ដេត អវត្តមាននាពេលសវនាការ ដោយជនជាប់ចោទបានរត់គេចខ្លួន ហើយចៅក្រមស៊ើបសួរក៏បានចេញដីកាបង្គាប់ឲ្យចាប់ខ្លួនផងដែរ។ ជនជាប់ចោទត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ១ឆ្នាំ ដោយមានការព្រួយបារម្ភថា ជនជាប់ចោទគេចខ្លួននឹងអាចបន្តប្រព្រឹត្តបទល្មើសជាថ្មីទៀត ហេតុនេះគប្បីចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទ យកមកឃុំខ្លួនក្នុងពន្ធនាគារ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៦.វត្ថុចាប់យកមាន: គ្រឿងញៀនប្រភេទមេតំហ្វេតាមីនចំនួន ០២កញ្ចប់ ទម្ងន់ ១២.០២ក្រាម និងទូរស័ព្ទដៃ ០១គ្រឿងម៉ាកណូគាអ៊ុនចុចពិល ពណ៌ទឹកសមុទ្រ។ គប្បីតុលាការតុលាការសម្រេចរឹបអូស។

៧.នាពេលសវនាការតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ: ក្រោយពីបានសួរដេញដោលឃើញថា: កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ពិតជាមានករណី រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ: ២៧០៤ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២។ ស្នើសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ចាន់ដេត។

៨.លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានពិនិត្យសំណុំរឿង និងសួរដេញដោលឃើញថា អង្គហេតុការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សាវុធ នៅថ្ងៃកើតហេតុបានដកហូតឃើញមានគ្រឿងញៀនចំនួន ០២កញ្ចប់តូច។ ចំពោះអង្គហេតុទី១ មុនពេលឃាត់ខ្លួនឈ្មោះ [redacted] សាវុធ ចេះប្រើប្រាស់គ្រឿងញៀនតាំងពីខែមករា ឆ្នាំ២០២១ នៅពេលបើកបររថយន្ត កុំឲ្យងងុយដេក និងធ្លាប់បានរំលែកលក់ឲ្យតៃកុងរថយន្តដូចគ្នា។ អង្គហេតុទី២ នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] សាវុធ បានទិញគ្រឿងញៀនពីឈ្មោះ [redacted] ចាន់ដេត ពិតប្រាកមែន គោលបំណងយកមកទុកប្រើប្រាស់ ពុំទាន់បានយកមករំលែកលក់ទេ ដូច្នេះស្នើសុំឲ្យតុលាការពិចារណាដែលតំណាងអយ្យការបានលើកយកមកចោទប្រកាន់ យកមកជំនុំជម្រះថ្ងៃនេះ គឺអង្គហេតុថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ជាអង្គហេតុដែលឈ្មោះ អ៊ុយ សាវុធ ទៅទិញសារធាតុញៀនយកមកប្រើប្រាស់។ ស្នើសុំឲ្យតុលាការពិចារណាលើអង្គហេតុថ្ងៃចោទប្រកាន់ សុំឲ្យតុលាការលើកលែងការចោទប្រកាន់ពីបទរក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយពិចារណាលើមាត្រា ៥៥ នៃច្បាប់ស្តីពីការគ្រួតពិនិត្យគ្រឿងញៀន។ ផ្អែកលើស្ថានភាពជាក់ស្តែង ដោយជនជាប់ចោទមានកូនក្នុងបន្ទុកចំនួន ០៤នាក់ និងមានក្មួយស្រីម្នាក់មករស់នៅជាមួយ ហើយប្រពន្ធរកស៊ីលក់ចាប់ហួយក្នុងភូមិតិចតួច ពុំមានលទ្ធភាពផ្គត់ផ្គង់ឲ្យកូនបានសិក្សាគ្រប់គ្រាន់ ស្នើសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ជនជាប់ចោទ។

ហេតុដូច្នេះសម្រេច

១.ផ្តន្ទាទោស:

ក.ឈ្មោះ [redacted] សាវុធ ភេទប្រុស អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ សាសនាព្រះពុទ្ធ។ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពត។ ទីលំនៅបច្ចុប្បន្នមុនចាប់ខ្លួននៅភូមិវាលធំ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ឪពុកឈ្មោះ [redacted] សាម៉ែត (ស) ម្តាយឈ្មោះ [redacted] ណាវី (ស) ប្រពន្ធឈ្មោះ [redacted] វណ្ណា (រ) មានកូន ០៤នាក់ ទោសពីមុន គ្មាន។

ដាក់ពន្ធនាគារកំណត់ចំនួន ៣ (បី) ឆ្នាំ ។ ទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារចំនួន ១៨ (ដប់ប្រាំបី) ខែ ទោសដែលនៅសល់ពីនេះត្រូវព្យួរការអនុវត្តធម្មតា យោងតាមមាត្រា ១០៤-១០៨ នៃក្រមព្រហ្មទណ្ឌ។

ខ.ឈ្មោះ [redacted]ចាន់ដេត ភេទប្រុស ឆ្នាំកំណើត១៩៨៩ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ១០០៧១៧៨៤៩។ ទីកន្លែងកំណើត[redacted]ខេត្តកំពង់ស្ពឺ។ ទីលំនៅបច្ចុប្បន្ននៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ។

ដាក់ពន្ធនាគារកំណត់ចំនួន ៣ (បី) ឆ្នាំ ។

ពីបទ: រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលធំ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ និងទោសដែលមានចែងក្នុងមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការគ្រួតពិនិត្យគ្រឿងញៀន។

២.វិបអូស: គ្រឿងញៀនប្រភេទមេតំហ្វេតាមីនចំនួន ០២កញ្ចប់ ទម្ងន់ ១២.០២ក្រាម និងទូរស័ព្ទដៃ ០១គ្រឿងម៉ាកណ្ងាគាអ៊ុនចុចពិល ពណ៌ទឹកសមុទ្រ។

៣.ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ចាន់ដេត ដែលមានសាវតាជាតិដូចខាងលើ និងយកមកឃុំខ្លួនក្នុងពន្ធនាគារតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សាវុធ និងកំចាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ដេត។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និងត្រា
[redacted]

ចៅក្រមជំនុំជម្រះ
ហត្ថលេខា និងត្រា
[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ២កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅខេត្តកំពង់ស្ពឺ. ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

បានឃើញ
ចៅក្រមជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner